**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ០៥ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ**

**របស់មន្ត្រីអធិការកិច្ចស្តង់ដារកម្ពុជា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៣ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីស្តង់ដារកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១១ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីស្តង់ដារកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចនៃវិទ្យាស្ថានស្តង់ដាកម្ពុជា ដែលសរសេរជាអក្សរកាត់ថា **វ.ស.ក**. និងមន្ត្រីអធិការកិច្ចតាមមន្ទីររាជធានី ខេត្តនៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សម្រាប់ប្រើប្រាស់នៅពេលបំពេញការងាររបស់អង្គភាព។

## ជំពូកទី២
## ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ
## ផ្នែកទី១
## ឯកសណ្ឋាន

**មាត្រា២ .-**

ឯកសណ្ឋានមន្ត្រីអធិការកិច្ចរបស់ **វ.ស.ក**. និងមន្ត្រីអធិការកិច្ចតាមមន្ទីររាជធានី ខេត្ត នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវបានកំណត់ដូចខាងក្រោម៖

ក- ឯកសណ្ឋានបុរស

១- ឯកសណ្ឋានបុរសសម្រាប់ប្រតិបត្តិការ៖

- អាវដៃខ្លីពណ៌ប្រផេះចាស់ កបើក ថ្នេរឌុប ប៉ូលស្មាសងខាង ជីបចង្កេះ សម្រុងជើងអាវត្រង់ស្មើឆែកពីក្រោយសងខាងតាមបណ្តោយខ្លួនប្រវែង២៥ស.ម. ហើយមានហោប៉ៅចំនួនបួន ហោប៉ៅខាងលើដេរបត់ផ្នត់កណ្តាលមានគម្របរាងស្លឹកពោធិ៍ ហោប៉ៅខាងក្រោមដេរបត់ប៉ះផ្នត់កណ្តាលមានគម្របរាងស្លឹកពោធិ៍ និងឡេវអាវមានត្រារូបព្រះសង្ការពណ៌មាសសម្រាប់ថ្នាក់អគ្គនាយក អគ្គនាយករងប្រធាននាយកដ្ឋាន ប្រធានមន្ទីររាជធានី ខេត្ត និងអនុប្រធាននាយកដ្ឋាន និងរូបព្រះសង្ការពណ៌ប្រាក់សម្រាប់ថ្នាក់អនុប្រធានមន្ទីររាជធានី ខេត្ត ប្រធានការិយាល័យ អនុប្រធានការិយាល័យ និងមន្ត្រី។ អាវដៃខ្លីនេះពាក់ពីខាងក្រៅ ហើយចំពោះអាវខាងក្នុង គឺអាវយឺតពណ៌សដៃខ្លី សម្រាប់ប្រើក្នុងប្រតិបត្តិការ
- ខោជើងវែងពណ៌ប្រផេះចាស់ ដេរថ្នេរបង្កប់ ចង្កេះត ជីបភ្លីខាងមុខពីរ មានហោប៉ៅចំនួនបីហោប៉ៅខាងក្រោយ មួយដេរបង្កប់មានគម្របរាងស្លឹកពោធិ៍ ចោះរន្ធដាក់ឡេវចំនួនមួយ និងហោប៉ៅចំហៀងទាំងសងខាងដេរថ្នេរបង្កប់តាមថ្នេរ
- ស្បែកជើងពណ៌ខ្មៅ ស្រោមជើងពណ៌ខ្មៅ
- ខ្សែក្រវាត់ពណ៌ខ្មៅ ក្បាលខ្សែក្រវាត់មានរូបព្រះសង្ការពណ៌មាស សម្រាប់ថ្នាក់អគ្គនាយក អគ្គនាយករងប្រធាននាយកដ្ឋាន ប្រធានមន្ទីររាជធានី ខេត្ត និងអនុប្រធាននាយកដ្ឋាន។ ក្បាលខ្សែក្រវាត់ពណ៌ប្រាក់ត្រូវបានប្រើប្រាស់សម្រាប់ថ្នាក់អនុប្រធានមន្ទីររាជធានី ខេត្ត ប្រធានការិយាល័យ អនុប្រធានការិយាល័យ និងមន្ត្រី។

២- ឯកសណ្ឋានបុរសសម្រាប់ពិធីការ៖

- អាវដៃវែងពណ៌ប្រផេះចាស់ កបើក ថ្នេរឌុប ប៉ូលស្មាសងខាង ជីបភ្លីខាងមុខពីរ ឡេវធំមានត្រារូបព្រះសង្ការពណ៌មាសសម្រាប់ថ្នាក់អគ្គនាយក អគ្គនាយករង ប្រធាននាយកដ្ឋាន ប្រធានមន្ទីរ

រាជធានី ខេត្ត និងអនុប្រធាននាយកដ្ឋាន និងរូបព្រះសង្ខារពណ៌ប្រាក់សម្រាប់ថ្នាក់អនុប្រធានមន្ទីរ រាជធានី ខេត្ត ប្រធានការិយាល័យ អនុប្រធានការិយាល័យ និងមន្ត្រី ពីក្រោមហូតដល់លើសម្រុង ជើងអាវត្រង់ស្មើ ផែកពីក្រោយសងខាងតាមបណ្ដោយខ្លួនប្រវែង២៥ស.ម. ហើយមានហោប៉ៅ ចំនួនបួន ហោប៉ៅខាងលើដេរបត់ផ្នត់កណ្ដាលមានគម្របរាងស្លឹកពោធិ៍ ហោប៉ៅខាងក្រោមដេរ គ្មានផ្នត់កណ្ដាល មានគម្របរាងចតុកោណកែង ផ្នែកខាងក្រោយមានដឹបក្លីចំនួនពីរ និងមានផែក ចំកណ្ដាលនៃអាវ។ អាវដៃវែងនេះពាក់ពីខាងក្រៅ ហើយចំពោះអាវខាងក្នុង គឺអាវសឺមីពណ៌សដៃវែង ក្រវាត់កពណ៌ទឹកប៊ិច សម្រាប់ប្រើក្នុងពិធីការតែប៉ុណ្ណោះ

- ខោជើងវែងពណ៌ប្រផេះចាស់ ដេរថ្នេរបង្កប់ ចង្កេះត ដឹបក្លីខាងមុខពីរ មានហោប៉ៅចំនួនបីហោប៉ៅ ខាងក្រោយ មួយដេរបង្កប់មានគម្របរាងស្លឹកពោធិ៍ បោះរន្ធដាក់ឡេវចំនួនមួយ និងហោប៉ៅចំហៀង ទាំងសងខាងដេរថ្នេរបង្កប់តាមថ្នេរ
- ស្បែកជើងពណ៌ខ្មៅ ស្រោមជើងពណ៌ខ្មៅ
- ខ្សែក្រវាត់ពណ៌ខ្មៅ ក្បាលខ្សែក្រវាត់មានរូបព្រះសង្ខារពណ៌មាស សម្រាប់ថ្នាក់អគ្គនាយក អគ្គនាយករង ប្រធាននាយកដ្ឋាន ប្រធានមន្ទីររាជធានី ខេត្ត និងអនុប្រធាននាយកដ្ឋាន។ ក្បាលខ្សែក្រវាត់ពណ៌ប្រាក់ ត្រូវបានប្រើប្រាស់សម្រាប់ថ្នាក់អនុប្រធានមន្ទីររាជធានី ខេត្ត ប្រធានការិយាល័យ អនុប្រធានការិយាល័យ និងមន្ត្រី។

៣_ ឯកសណ្ឋានបុរសសម្រាប់ការងារ៖

អាវដៃវែង មានពណ៌ប្រផេះចាស់ កឱប ថ្នេរឱប បោះឡេវចុងក ប៉ូលស្មា មានហោប៉ៅពីរដេរប៉ះ បត់ផ្នត់កណ្ដាល មានគម្របរាងស្លឹកពោធិ៍ កាត់ស្រុងវែង ជើងត្រង់ដាក់ក្នុងខោ។

**ខ_ ឯកសណ្ឋាននារី**

- អាវម៉ូតដូចបុរសទាំងអស់ ប៉ុន្តែកអាវមានរាងកអាវរបស់នារី
- ខោម៉ូតដូចបុរស ប៉ុន្តែគ្មានហោប៉ៅក្រោយ មានពណ៌ប្រផេះចាស់ ឬសំពត់ហ្ស៊ីបពណ៌ប្រផេះចាស់ សម្រុង ជើងក្រោមជង្គង់ ផែកក្រោយ រូតចំហៀង
- ស្បែកជើងពណ៌ខ្មៅ ស្រោមជើងពណ៌ខ្មៅ
- ខ្សែក្រវាត់ពណ៌ខ្មៅ ក្បាលខ្សែក្រវាត់មានរូបព្រះសង្ខារពណ៌មាស សម្រាប់ថ្នាក់អគ្គនាយក អគ្គនាយករង ប្រធាននាយកដ្ឋាន ប្រធានមន្ទីររាជធានី ខេត្ត និងអនុប្រធាននាយកដ្ឋាន។ ក្បាលខ្សែក្រវាត់ពណ៌ប្រាក់ ត្រូវបានប្រើប្រាស់សម្រាប់ថ្នាក់អនុប្រធានមន្ទីររាជធានី ខេត្ត ប្រធានការិយាល័យ អនុប្រធានការិយាល័យ និងមន្ត្រី។

គំរូនៃឯកសណ្ឋានត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ។

**មាត្រា៣ ._**

មួកកាស្កែត ត្រូវបានរៀបចំជា៥(ប្រាំ)ថ្នាក់៖

១_ **ថ្នាក់អគ្គនាយកវិទ្យាស្ថានស្តង់ដារកម្ពុជា** : មួកកាស្កែតធ្វើពីកំណាត់ពណ៌ដូចអាវ ផ្នែកខាងមុខលើ កណ្ដាប់វណ្ឌមានភ្ជាប់រូបព្រះសង្ខារពណ៌មាសទំហំកម្ពស់៧,៨ស.ម. ទទឹង៦,៨ស.ម. ផ្នែកខាងក្រោម នៃជើងមួក និងក្រោមព្រះសង្ខារ មានក្បាច់ភ្ញីទេសប៉ាក់ពណ៌មាសដល់ជើងមួកនិងខាងក្រោមក្បាច់ មានប៉ាក់វណ្ឌពួរពណ៌មាសពីលើកំណាត់ឡែនពណ៌ប្រផេះស្រាលព័ទ្ធជុំវិញ ព្រមទាំងនៅខាងចុង ខ្សែវណ្ឌទាំងពីរខាងមានភ្ជាប់ឡេវរូបព្រះសង្ខារពណ៌មាស។ ខាងក្រោមនៃប៉ាក់វណ្ឌផ្នែកខាងមុខមាន ក្បាំងពណ៌ខ្មៅ នៅលើក្បាំងមានប៉ានក្បាច់ភ្ញីទេសប៉ាក់ពណ៌មាសទម្រង់ស្នែងក្របីធំដល់ជើងមួក។

២. **ថ្នាក់អគ្គនាយករងវិទ្យាស្ថានស្តង់ដារកម្ពុជា** : មួកកាស្កែតធ្វើពីកំណាត់ពណ៌ដូចអាវ ផ្នែកខាងមុខលើកណ្តាប់វណ្ឌមានភ្ជាប់រូបព្រះសង្ហារពណ៌មាសទំហំកម្ពស់៧,៨ស.ម. ទទឹង៦,៨ស.ម. ផ្នែកខាងក្រោមនៃជើងមួក និងក្រោមរូបព្រះសង្ហារ មានប៉ាក់វណ្ឌពួរពណ៌មាសពីលើកំណាត់ខ្សៀនពណ៌ប្រផេះស្រាលព័ទ្ធជុំវិញ ព្រមទាំងនៅខាងចុងខ្សែវណ្ឌទាំងពីរខាងភ្ជាប់ដោយឡេវរូបព្រះសង្ហារពណ៌មាស។ ខាងក្រោមនៃប៉ាក់វណ្ឌផ្នែកខាងមុខមានក្បាំងពណ៌ខ្មៅនៅលើក្បាំងមានប៉ានក្បាច់ភ្ញីទេសប៉ាក់ពណ៌មាស ទម្រង់ស្នែងក្របីធំដល់ជើងមួក។

៣. **ថ្នាក់ប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន ប្រធានមន្ទីរ** : មួកកាស្កែតធ្វើពីកំណាត់ពណ៌ដូចអាវ ផ្នែកខាងមុខលើកណ្តាប់វណ្ឌមានភ្ជាប់រូបព្រះសង្ហារពណ៌មាសទំហំកម្ពស់៧,៨ស.ម. ទទឹង៦,៨ស.ម. ផ្នែកខាងក្រោមនៃជើងមួក និងក្រោមព្រះសង្ហារមានកណ្តាប់វណ្ឌពណ៌មាស នៅពីលើកំណាត់ខ្សៀនពណ៌ប្រផេះស្រាលព័ទ្ធជុំវិញ។ ខាងក្រោមកណ្តាប់វណ្ឌផ្នែកខាងមុខមានក្បាំងពណ៌ខ្មៅ។ ផ្នែកខាងក្រោមកណ្តាប់វណ្ឌដែលនៅពីលើក្បាំងមានកម្រងខ្សែសយពណ៌មាសនៅខាងចុងកម្រងខ្សែសយទាំងពីរ មានភ្ជាប់ឡេវព្រះសង្ហារពណ៌មាស។ នៅលើក្បាំងមួកមានប៉ានក្បាច់ភ្ញីទេសប៉ាក់ពណ៌មាសទម្រង់ស្នែងក្របីធំដល់ជើងមួក។

៤. **ថ្នាក់ប្រធានការិយាល័យ អនុប្រធានការិយាល័យ អនុប្រធានមន្ទីរ ប្រធានការិយាល័យនៃមន្ទីរ** : មួកកាស្កែត ធ្វើពីកំណាត់ពណ៌ដូចអាវ ផ្នែកខាងមុខលើកណ្តាប់វណ្ឌមានភ្ជាប់រូបព្រះសង្ហារពណ៌ប្រាក់ទំហំកម្ពស់ ៧,៨ស.ម. ទទឹង៦,៨ស.ម. ផ្នែកខាងក្រោមនៃជើងមួក និងក្រោមព្រះសង្ហារមានកណ្តាប់វណ្ឌពណ៌ប្រាក់ ធ្វើពីលើកំណាត់ខ្សៀនពណ៌ប្រផេះស្រាលព័ទ្ធជុំវិញ។ ខាងក្រោមកណ្តាប់វណ្ឌផ្នែកខាងមុខមានក្បាំងពណ៌ខ្មៅ។ ផ្នែកខាងក្រោមកណ្តាប់វណ្ឌដែលនៅពីលើក្បាំងមានកម្រងខ្សែសយពណ៌ប្រាក់ ព្រមទាំង នៅសងខាងចុងខ្សែទាំងពីរខាងភ្ជាប់ដោយឡេវព្រះសង្ហារពណ៌ប្រាក់។ នៅលើក្បាំងមួកមានប៉ានក្បាច់ ភ្ញីទេសប៉ាក់ពណ៌ប្រាក់ទម្រង់ស្នែងក្របី ដោយចុងសងខាងទុកចន្លោះ៤ស.ម. ពីជើងមួក។

៥. **ថ្នាក់មន្ត្រី អនុប្រធានការិយាល័យនៃមន្ទីរ និងមន្ត្រីនៃមន្ទីរ** : មួកកាស្កែតធ្វើពីកំណាត់ពណ៌ដូចអាវ ផ្នែកខាងមុខលើកណ្តាប់វណ្ឌមានភ្ជាប់រូបព្រះសង្ហារពណ៌ប្រាក់ទំហំកម្ពស់៧,៨ស.ម. ទទឹង៦,៨ស.ម. ផ្នែកខាងក្រោម នៃជើងមួក និងក្រោមព្រះសង្ហារមានកណ្តាប់វណ្ឌពណ៌ប្រាក់ធ្វើពីលើកំណាត់ខ្សៀនពណ៌ប្រផេះស្រាលព័ទ្ធជុំវិញ។ ខាងក្រោមកណ្តាប់វណ្ឌផ្នែកខាងមុខមានក្បាំងពណ៌ខ្មៅ។ ផ្នែកខាងក្រោមកណ្តាប់វណ្ឌដែលនៅលើក្បាំងមានកម្រងខ្សែសយពណ៌ប្រាក់ ព្រមទាំងនៅសងខាងចុងខ្សែទាំងពីរខាងភ្ជាប់ដោយ ឡេវព្រះសង្ហារពណ៌ប្រាក់។ នៅលើក្បាំងមួកគ្មានប៉ានក្បាច់ភ្ញីទេសទេ។

គំរូនៃមួកត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

## ផ្នែកទី២
## សញ្ញាសម្គាល់

**មាត្រា៤ .-**

សញ្ញាពាក់នៅលើដៃអាវខាងស្តាំ ជាសញ្ញាក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ធ្វើអំពីកំណាត់ក្រាស់រាងជារង្វង់មានអង្កត់ផ្ចិតប្រវែង៨ស.ម.។ សញ្ញាពាក់នៅលើដៃអាវខាងឆ្វេង ជាសញ្ញាវិទ្យាស្ថានស្តង់ដារកម្ពុជា ធ្វើអំពីកំណាត់ក្រាស់រាងជារង្វង់មានអង្កត់ផ្ចិតប្រវែង៨ស.ម.។ សញ្ញាសម្គាល់នេះប្រើប្រាស់លើគ្រប់ឯកសណ្ឋានទាំងអស់។

គំរូនៃសញ្ញាសម្គាល់លើដៃអាវខាងឆ្វេងនិងខាងស្តាំ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៣នៃអនុក្រឹត្យនេះ។

**មាត្រា៥ ..**

សញ្ញាសម្គាល់វិទ្យាស្ថានស្តង់ដារកម្ពុជាមានរាងមូលប៉ោងទំហំ៤,៧ស.ម. ធ្វើអំពីស្ពាន់ភ្ជាប់ដោយបន្ទះស្បែកសម្រាប់ពាក់នៅលើហោប៉ៅអាវស្តាំដៃ។ សញ្ញាសម្គាល់នេះ ប្រើសម្រាប់បំពាក់នៅលើឯកសណ្ឋានប្រតិបត្តិការ និងពិធីការតែប៉ុណ្ណោះ ដោយលើកលែងចំពោះឯកសណ្ឋានការងារ។

គំរូនៃសញ្ញាសម្គាល់រាងមូលប៉ោងលើហោប៉ៅអាវស្តាំដៃ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៤នៃអនុក្រឹត្យនេះ។

**មាត្រា៦ ..**

សញ្ញាសម្គាល់ឈ្មោះមន្ត្រីអធិការកិច្ច សម្រាប់ពាក់នៅពីលើហោប៉ៅអាវខាងស្តាំមានរាងចតុកោណកែង ដែលមានបណ្តោយប្រវែង៩,៥ស.ម. ទទឹង២ស.ម. ដែលសរសេរអក្សរពណ៌ទឹកមាស និងពាសដោយជ័រវីងថ្លា មានផ្ទៃពណ៌ខ្មៅ និងមានខ្សែបន្ទាត់ស្តើងពណ៌មាសព័ទ្ធជុំវិញ ដែលមានទំហំ០,១៥ស.ម.។ ប៉ែកខាងស្តាំដៃនៃស្លាកឈ្មោះមានសញ្ញាក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងប៉ែកខាងឆ្វេង មានសរសេរគោត្តនាម និងនាមជាអក្សរខ្មែរ អក្សរឡាតាំង និងមានអត្តលេខរបស់មន្ត្រីរាជការ។ សញ្ញាសម្គាល់នេះ ប្រើប្រាស់លើគ្រប់ឯកសណ្ឋានទាំងអស់។

គំរូនៃសញ្ញាសម្គាល់ឈ្មោះមន្ត្រីអធិការកិច្ច ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៥នៃអនុក្រឹត្យនេះ។

**មាត្រា៧ ..**

សញ្ញាសម្គាល់សម្រាប់ពាក់លើចុងកអាវ ឆ្វេង ស្តាំ មានរាងមូល ទំហំ២,៥ស.ម. និងមានរូបសញ្ញាវិទ្យាស្ថានស្តង់ដារកម្ពុជា ធ្វើពីស្ពាន់ និងក្រូមេពណ៌មាសសម្រាប់ថ្នាក់អគ្គនាយក អគ្គនាយករង ប្រធាននាយកដ្ឋាន ប្រធានមន្ទីររាជធានី ខេត្ត និងអនុប្រធាននាយកដ្ឋាន និងក្រូមេពណ៌ប្រាក់សម្រាប់ថ្នាក់អនុប្រធានមន្ទីររាជធានី ខេត្ត ប្រធានការិយាល័យ អនុប្រធានការិយាល័យ និងមន្ត្រី។

សញ្ញាសម្គាល់នេះ ប្រើប្រាស់ជាមួយ អាវប្រតិបត្តិការនិងអាវពិធីការ។

គំរូនៃសញ្ញាសម្គាល់ពាក់លើចុងកអាវឆ្វេងស្តាំ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៦នៃអនុក្រឹត្យនេះ។

## ផ្នែកទី៣
## សញ្ញាសក្តិ

**មាត្រា៨ ..**

សញ្ញាសក្តិស្មា ត្រូវបានកំណត់ដូចខាងក្រោម៖

- បាតក្រោមប្រវែង៦ស.ម.
- បណ្តោយពីលើបាតក្រោមប្រវែង១៣ស.ម.
- ទទឹងមុខកាត់ផ្នែកខាងលើប្រវែង៤,៧ស.ម. មានរាងកោងជាមុំទាល។

សញ្ញាសក្តិស្មា ត្រូវបានកំណត់ជា៨ថ្នាក់ខុសៗគ្នា ដូចខាងក្រោម៖

- ថ្នាក់អគ្គនាយក
- ថ្នាក់អគ្គនាយករង
- ថ្នាក់ប្រធាននាយកដ្ឋាន
- ថ្នាក់អនុប្រធាននាយកដ្ឋាននិងប្រធានមន្ទីរ
- ថ្នាក់ប្រធានការិយាល័យថ្នាក់កណ្តាលនិងអនុប្រធានមន្ទីរ
- ថ្នាក់អនុប្រធានការិយាល័យថ្នាក់កណ្តាលនិងប្រធានការិយាល័យនៃមន្ទីរ
- ថ្នាក់មន្ត្រីថ្នាក់កណ្តាលនិងអនុប្រធានការិយាល័យនៃមន្ទីរ និង
- ថ្នាក់មន្ត្រីនៃមន្ទីរ។

១. **ថ្នាក់អគ្គនាយកវិទ្យាស្ថានស្តង់ដារកម្ពុជា** : ផ្ទៃពណ៌ខ្មៅ ដែលព័ទ្ធជុំវិញដោយក្បាច់ភ្ញីទេសពណ៌មាស មានសញ្ញាវិទ្យាស្ថានស្តង់ដារកម្ពុជាជាពណ៌មាសនៅចំកណ្តាល ផ្នែកខាងចុងនៃសញ្ញាសក្តិមានរូបព្រះសង្ខារ និងផ្នែកខាងក្រោមនៃសញ្ញាសក្តិមានរូបផ្កាទម្រង់ក្បាច់កញ្ចាំងអង្គរពណ៌មាសចំនួន៤ (បួន)។

២. **ថ្នាក់អគ្គនាយករងវិទ្យាស្ថានស្តង់ដារកម្ពុជា** : ផ្ទៃពណ៌ខ្មៅ ដែលព័ទ្ធជុំវិញដោយក្បាច់ភ្ញីទេសពណ៌មាស មានសញ្ញាវិទ្យាស្ថានស្តង់ដារកម្ពុជាជាពណ៌មាសនៅចំកណ្តាល ផ្នែកខាងចុងនៃសញ្ញាសក្តិមានរូបព្រះសង្ខារ និងផ្នែកខាងក្រោមនៃសញ្ញាសក្តិមានរូបផ្កាទម្រង់ក្បាច់កញ្ចាំងអង្គរពណ៌មាសចំនួន៣(បី)។

៣. **ថ្នាក់ប្រធាននាយកដ្ឋាន** : ផ្ទៃពណ៌ខ្មៅ ដែលព័ទ្ធជុំវិញដោយក្បាច់ភ្ញីទេសពណ៌មាស មានសញ្ញាវិទ្យាស្ថានស្តង់ដារកម្ពុជាជាពណ៌មាសនៅចំកណ្តាល ផ្នែកខាងចុងនៃសញ្ញាសក្តិមានរូបព្រះសង្ខារ និងផ្នែកខាងក្រោមនៃសញ្ញាសក្តិមានរូបផ្កាទម្រង់ក្បាច់កញ្ចាំងអង្គរពណ៌មាសចំនួន២(ពីរ)។

៤. **ថ្នាក់អនុប្រធាននាយកដ្ឋាននិងប្រធានមន្ទីរ** : ផ្ទៃពណ៌ខ្មៅ ដែលព័ទ្ធជុំវិញដោយក្បាច់ភ្ញីទេសពណ៌មាស មានសញ្ញាវិទ្យាស្ថានស្តង់ដារកម្ពុជាជាពណ៌មាសនៅចំកណ្តាល ផ្នែកខាងចុងនៃសញ្ញាសក្តិមានរូបព្រះសង្ខារ និងផ្នែកខាងក្រោមនៃសញ្ញាសក្តិមានរូបផ្កាទម្រង់ក្បាច់កញ្ចាំងអង្គរពណ៌មាសចំនួន១(មួយ)។

៥. **ថ្នាក់ប្រធានការិយាល័យនិងអនុប្រធានមន្ទីរ** : ផ្ទៃពណ៌ខ្មៅ ដែលព័ទ្ធជុំវិញដោយក្បាច់ភ្ញីទេសពណ៌ប្រាក់ មានសញ្ញាវិទ្យាស្ថានស្តង់ដារកម្ពុជាជាពណ៌ប្រាក់ នៅចំកណ្តាល ផ្នែកខាងចុងនៃសញ្ញាសក្តិមានរូបព្រះសង្ខារ និងផ្នែកខាងក្រោមនៃសញ្ញាសក្តិមានរូបផ្កាទម្រង់ក្បាច់កញ្ចាំងអង្គរពណ៌ប្រាក់ចំនួន៣(បី)។

៦. **ថ្នាក់អនុប្រធានការិយាល័យនិងប្រធានការិយាល័យនៃមន្ទីរ** : ផ្ទៃពណ៌ខ្មៅ ដែលព័ទ្ធជុំវិញដោយក្បាច់ភ្ញីទេសពណ៌ប្រាក់ មានសញ្ញាវិទ្យាស្ថានស្តង់ដារកម្ពុជាជាពណ៌ប្រាក់ នៅចំកណ្តាល ផ្នែកខាងចុងនៃសញ្ញាសក្តិមានរូបព្រះសង្ខារ និងផ្នែកខាងក្រោមនៃសញ្ញាសក្តិមានរូបផ្កាទម្រង់ក្បាច់កញ្ចាំងអង្គរពណ៌ប្រាក់ចំនួន២(ពីរ)។

៧. **ថ្នាក់មន្ត្រីនិងអនុប្រធានការិយាល័យនៃមន្ទីរ** : ផ្ទៃពណ៌ខ្មៅ ដែលព័ទ្ធជុំវិញដោយក្បាច់ភ្ញីទេសពណ៌ប្រាក់ មានសញ្ញាវិទ្យាស្ថានស្តង់ដារកម្ពុជាជាពណ៌ប្រាក់ នៅចំកណ្តាល ផ្នែកខាងចុងនៃសញ្ញាសក្តិមានរូបព្រះសង្ខារ និងផ្នែកខាងក្រោមនៃសញ្ញាសក្តិមានរូបផ្កាទម្រង់ក្បាច់កញ្ចាំងអង្គរពណ៌ប្រាក់ចំនួន១ (មួយ)។

៨. **ថ្នាក់មន្ត្រីនៃមន្ទីរ** : ផ្ទៃពណ៌ខ្មៅ ដែលព័ទ្ធជុំវិញដោយក្បាច់ភ្ញីទេសពណ៌ប្រាក់ មានសញ្ញាវិទ្យាស្ថានស្តង់ដារកម្ពុជាជាពណ៌ប្រាក់ នៅចំកណ្តាល ផ្នែកខាងចុងនៃសញ្ញាសក្តិមានរូបព្រះសង្ខារ។

គំរូនៃសញ្ញាសក្តិ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៧នៃអនុក្រឹត្យនេះ។

## ជំពូកទី៣
## ការផ្តល់និងការប្រើប្រាស់ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ

**មាត្រា៩ .-**

មន្ត្រីអធិការកិច្ច **វ.ស.ក**. និងមន្ត្រីអធិការកិច្ចតាមមន្ទីររាជធានី ខេត្ត នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវទទួលបាននូវរបបឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ ដូចបានកំណត់ក្នុងអនុក្រឹត្យនេះ ជារៀងរាល់ឆ្នាំតាមថ្នាក់របស់មន្ត្រីម្នាក់ៗ និងការកំណត់ដូចខាងក្រោម៖

- មួកកាស្កេតចំនួន១(មួយ)
- អាវការងារមានដេរភ្ជាប់សញ្ញាសម្គាល់ដូចមានចែងក្នុងមាត្រា៥ ចំនួន២(ពីរ)
- អាវប្រតិបត្តិការមានដេរភ្ជាប់សញ្ញាសម្គាល់ដូចមានចែងក្នុងមាត្រា៥ ចំនួន២(ពីរ)
- អាវពិធីការមានដេរភ្ជាប់សញ្ញាសម្គាល់ដូចមានចែងក្នុងមាត្រា៥ ចំនួន១(មួយ)
- សញ្ញាសម្គាល់មួលប៉ោងដូចមានចែងក្នុងមាត្រា៥ ចំនួន១(មួយ)
- សញ្ញាសម្គាល់ឈ្មោះមន្ត្រីអធិការកិច្ចដូចមានចែងក្នុងមាត្រា៦ ចំនួន១(មួយ)
- សញ្ញាសម្គាល់ **ឧ.ស.ក**. សម្រាប់ពាក់លើចុងកអាវ ឆ្វេង ស្តាំ ដូចមានចែងក្នុងមាត្រា៧ ចំនួន ១(មួយ)គូ
- សញ្ញាសក្តិចំនួន១(មួយ)គូ
- ខោឬសំពត់ចំនួន២(ពីរ)
- ស្បែកជើងបុរសឬនារីចំនួនមួយគូនិងស្រោមជើងចំនួន២(ពីរ)គូ
- ក្រវាត់កចំនួន១(មួយ)និងខ្សែក្រវាត់ចំនួន១(មួយ)។

គំរូនៃរូបទាំងស្រុងនៃឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចស្តង់ដារកម្ពុជាត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៨នៃអនុក្រឹត្យនេះ។

**មាត្រា១០ .-**

មន្ត្រីអធិការកិច្ច **ឧ.ស.ក**. និងមន្ត្រីអធិការកិច្ចមន្ទីររាជធានី ខេត្ត នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវស្លៀកពាក់ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ និងត្រូវមានបណ្ណសម្គាល់ខ្លួនមន្ត្រីរាជការ លិខិតបញ្ជាបេសកកម្ម ឬលិខិតឧទ្ទេសនាម ក្នុងពេលបំពេញបេសកកម្ម។ ក្នុងពិធីប្រជុំឬពិធីការផ្សេងៗទៀត បើចាំបាច់ ត្រូវស្លៀកពាក់ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ ដូចមានចែងក្នុងអនុក្រឹត្យនេះ។

## ជំពូកទី៤
## ទោសប្បញ្ញត្តិ

**មាត្រា១១ .-**

ជនណាដែលបានក្លែងឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ ឬក្លែងបន្លំខ្លួនដោយស្លៀកពាក់ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ របស់មន្ត្រីអធិការកិច្ចស្តង់ដារកម្ពុជា ត្រូវផ្តន្ទាទោសទៅតាមច្បាប់ជាធរមាន។

## ជំពូកទី៥
## អន្តរប្បញ្ញត្តិ

**មាត្រា១២ .-**

ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចស្តង់ដារកម្ពុជាដែលកំពុងប្រើប្រាស់បច្ចុប្បន្ន ត្រូវបន្តរហូតដល់មានឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិថ្មីមកជំនួសស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃច័ន្ទ ១៣ រោច ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១១ ខែមករា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

**កិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ**

**កន្លែងទទួល**:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធទី១**

**នៃអនុក្រឹត្យលេខ**......០៥ អនក្រ.បក......**ចុះថ្ងៃទី**......៦......**ខែ**...មករា...**ឆ្នាំ**...២០២១...

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចស្តង់ដារកម្ពុជា**

**គំរូនៃឯកសណ្ឋាន**

**គំរូខោ**



**មុខ** **ក្រោយ**

**គំរូសំពត់នារី**



**មុខ** **ក្រោយ**

**គំរូក្រវាត់កពណ៌ទឹកប៊ិច**



**គំរូខ្សែក្រវាត់**



**គំរូស្បែកជើងបុរស**



**គំរូស្បែកជើងនារី**



**គំរូស្រោមជើងពណ៌ខ្មៅ**



**គំរូនៃអាវការងារសម្រាប់បុរសនិងនារី**
**មានរាងប្រហាក់ប្រហែលគ្នា**



**គំរូនៃឯកសណ្ឋានពិធីការ**



**គំរូនៃឯកសណ្ឋានប្រតិបត្តិការនារី**



**គំរូនៃឯកសណ្ឋានប្រតិបត្តិការបុរសសម្រាប់ថ្នាក់អគ្គនាយក អគ្គនាយករង ប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន និងប្រធានមន្ទីររាជធានី ខេត្ត**



**គំរូនៃឯកសណ្ឋានប្រតិបត្តិការបុរសសម្រាប់ថ្នាក់អនុប្រធានមន្ទីររាជធានី ខេត្ត ប្រធានការិយាល័យ អនុប្រធានការិយាល័យ និងមន្ត្រី**



## ឧបសម្ព័ន្ធទី២

នៃអនុក្រឹត្យលេខ.....០៥ អនក្រ.បក.....ចុះថ្ងៃទី.....៦.....ខែ.....មករា.....ឆ្នាំ.....២០២១

ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចស្តង់ដារកម្ពុជា

### គំរូនៃមួក

១. ថ្នាក់អគ្គនាយក



២. ថ្នាក់អគ្គនាយករង



៣. ថ្នាក់ប្រធាននិងអនុប្រធាននាយកដ្ឋាន និងប្រធានមន្ទីរ



៤. ថ្នាក់ប្រធានការិយាល័យ អនុប្រធានការិយាល័យ អនុប្រធានមន្ទីរ និងប្រធានការិយាល័យនៃមន្ទីរ



៥. ថ្នាក់មន្ត្រី អនុប្រធានការិយាល័យនៃមន្ទីរ និងមន្ត្រីនៃមន្ទីរ



**ឧបសម្ព័ន្ធទី៣**

**នៃអនុក្រឹត្យលេខ.....០៥ អនក្រ.បក.....ចុះថ្ងៃទី.....៦.....ខែ.....មករា.....ឆ្នាំ.....២០២១**

**ស្ដីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចស្តង់ដារកម្ពុជា**

**គំរូនៃសញ្ញាសម្គាល់**

**១- គំរូនៃសញ្ញាសម្គាល់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សម្រាប់ដាក់លើដៃអាវខាងស្តាំ**

**២- គំរូនៃសញ្ញាសម្គាល់វិទ្យាស្ថានស្តង់ដារកម្ពុជាសម្រាប់ដាក់លើដៃអាវខាងឆ្វេង**

**ឧបសម្ព័ន្ធទី៤**

**នៃអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី ៦ ខែ មករា ឆ្នាំ ២០២១**

**ស្ដីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចស្តង់ដារកម្ពុជា**

**គំរូនៃសញ្ញាសម្គាល់រាងមូលប៉ោងនៅលើហោប៉ៅអាវខាងស្ដាំ**



**ឧបសម្ព័ន្ធទី៥**
**នៃអនុក្រឹត្យលេខ** ០៥ អនក្រ.បក **ចុះថ្ងៃទី** ៦ **ខែ** មករា **ឆ្នាំ** ២០២១
**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចស្តង់ដារកម្ពុជា**

**គំរូនៃសញ្ញាសម្គាល់ឈ្មោះមន្ត្រីអធិការកិច្ច**



**ឧបសម្ព័ន្ធទី៦**

**នៃអនុក្រឹត្យលេខ...០៥ អនក្រ.បក...ចុះថ្ងៃទី...៦...ខែ...មករា...ឆ្នាំ...២០២១...**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចស្តង់ដារកម្ពុជា**

**គំរូនៃសញ្ញាសម្គាល់ពាក់លើចុងកអាវឆ្វេងស្តាំ**

**ថ្នាក់អគ្គនាយក អគ្គនាយករង ប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន**
**និងប្រធានមន្ទីររាជធានី ខេត្ត**




**ថ្នាក់អនុប្រធានមន្ទីររាជធានី ខេត្ត ប្រធានការិយាល័យ**
**អនុប្រធានការិយាល័យ និងមន្ត្រី**



## ឧបសម្ព័ន្ធទី៧

នៃអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី ៦ ខែ មករា ឆ្នាំ ២០២១

ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចស្តង់ដារកម្ពុជា

### គំរូនៃសញ្ញាសក្តិ

១- ថ្នាក់អគ្គនាយក



២- ថ្នាក់អគ្គនាយករង



៣- ថ្នាក់ប្រធាននាយកដ្ឋាន



៤- ថ្នាក់អនុប្រធាននាយកដ្ឋាន និងប្រធានមន្ទីរ



៥- ថ្នាក់ប្រធានការិ. និងអនុប្រធានមន្ទីរ



៦- ថ្នាក់អនុប្រធានការិ. និងប្រធានការិ.នៃមន្ទីរ



៧- ថ្នាក់មន្ត្រីថ្នាក់កណ្តាល និងអនុប្រធានការិ.នៃមន្ទីរ



៨- ថ្នាក់មន្ត្រីនៃមន្ទីរ



**ឧបសម្ព័ន្ធទី៨**

**នៃអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ៦ ខែ មករា ឆ្នាំ ២០២១**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចស្តង់ដារកម្ពុជា**

**គំរូនៃរូបទាំងស្រុង**

**នៃឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចស្តង់ដារកម្ពុជា**

